# ហាកាយ ២:១០-២៣

## ព្រះប្រទានពរដល់មនុស្សទុច្ចរិតតាមរយៈពូជរបស់ស្តេចដាវីឌ

**ការរំលឹក:** ហាកាយ ២:១-៩ បានប្រកាសអំពីព្រះវិហារមួយដែលនឹងមានពួកសាសន៍ដទៃពីផែនដីទាំងមូលចូលរួម។ ទំនាយនេះបានសម្រេចតាមរយៈព្រះយេស៊ូវ។ ព្រះយេស៊ូវគឺជាព្រះវិហារដែលបានជំនួសព្រះវិហារនៅយេរូសាឡិម (យ៉ូហាន ២:១៩-២១)។

ហាកាយជំពូក២ បានចែងទុកនូវប្រសាសន៍បីដែលព្រះជាម្ចាស់បានប្រកាសដល់ប្រជាជនយូដា។ ប្រសាសន៍ទីពីរមាននៅក្នុង ២:១០-១៩ ហើយប្រសាសន៍ទីបីមាននៅក្នុង ២:២០-២៣។

ចូរបំពេញចន្លោះ

២:១ នៅថ្ងៃទី_____ ក្នុងខែទី_____

២:១០ នៅថ្ងៃទី_____ ក្នុងខែទី_____

២:២០ នៅថ្ងៃទី_____ ក្នុងខែទី_____

ដូច្នេះពី២:១ និង ២:១០ *តើ យើងឃើញថា មានប៉ុន្មានខែរវាងប្រសាសន៍របស់ហាកាយនៅក្នុង២:១-៩ ហើយប្រសាសន៍ទាំងពីរនៅក្នុង២:១០-២៣?*

ចូរអាន ខ.១១-១៤ *ព្រះជាម្ចាស់បានសួរសំនួរពីរ តើសំនួរទាំងនោះគឺជាអ្វី?*

**ការពន្យល់** សំនួរទាំងពីរបង្ហាញថា របស់មិនអាចក្លាយជាបរិសុទ្ធដោយសារតែប៉ះពាល់អ្វីដែលបរិសុទ្ធ ឬបានញែកជាសក្ការៈនោះទេ ប៉ុន្តែរបស់បានក្លាយជាសៅហ្មងដោយប៉ះពាល់អ្វីដែលសៅហ្មង (ជនគណនា ១៩:១១,២២)។ ព្រះជាម្ចាស់បានអនុវត្តគោលការណ៍នេះចំពោះជីវិតរបស់ពួកគេ ដោយមានគោលបំណងបង្រៀនថា អាកប្បកិរិយារបស់ពួកគេបាននាំអោយអ្វីៗដែលពួកគេធ្វើនិងអ្វីៗដែលគេយកមកថ្វាយដល់ព្រះអង្គក៏សៅហ្មងដែរ។ គេកាន់សាសនាហើយគេធ្វើពិធីសាសនាក៏ប៉ុន្តែព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យនូវពិធីនិងតង្វាយរបស់គេឡើយ។

**សំនួរឆ្លុះបញ្ចាំង** *តើយើងធ្លាប់បានធ្វើពិធីសាសនា ប៉ុន្តែយើងនៅតែមានជីវិតដែលមិនគាប់ព្រះហឫទ័យព្រះ ដោយសារអំពើនិងអាកប្បកិរិយារបស់យើងទេ?*

ចូរអាន ខ.១៥-១៩ *តើប្រភពនៃការទុក្ខវេទនារបស់គេគឺជាអ្វី?*

*ហេតុអ្វីបានជាព្រះជាម្ចាស់បានធ្វើអោយដំណាំរបស់ពួកគេខូចខាត?*

ដូច្នេះយើងឃើញថា ប្រជាជនមិនសូវយកចិត្តទុកដាក់ចំពោះការសាងសង់ព្រះវិហារ។ គេបានទទួលបណ្តាសាមកពីព្រះជាម្ចាស់ ប៉ុន្តែនៅក្នុងខ.១៩ ព្រះអង្គមានព្រះបន្ទូលថា ចាប់ពីថ្ងៃនេះទៅព្រះអង្គលែងដាក់បណ្តាសាលើពួកគេទៀតហើយ ប៉ុន្តែទ្រង់នឹងប្រទានពរវិញ។ តើព្រះអង្គនឹងប្រទានពរដោយរបៀបណា? ព្រះជាម្ចាស់បានបើកសំដែងព្រះបន្ទូលមួយទៀតនៅខ.២០-២៣ ដើម្បីឆ្លើយសំនួរនេះ។

ចូរអាន ខ.២០-២៣ *តើអត្ថបទនេះបានទាយអំពីអ្វី?*

**ការពន្យល់** កាលពីជិត៥០០ឆ្នាំមុន ព្រះជាម្ចាស់បានសន្យាថា ពូជពង្សរបស់ដាវីឌនឹងឡើងស្នងរាជ្យ ហើយនឹងពង្រឹងរាជបល្ល័ង្ករបស់គេ អោយនៅស្ថិតស្ថេររហូតតទៅ (២សាំយូអែល ៧:១២-១៣)។ នៅពេលបណ្តាជនបានទៅបាប៊ីឡូនពូជពង្សរបស់ដាវីឌលែងគ្រប់គ្រងជាស្តេចទៀតហើយ ដូច្នេះបណ្តាជនរិះគិតថា តើព្រះជាម្ចាស់ទ្រង់នឹងសំរេចតាមព្រះបន្ទូលសន្យានោះឬទេ? សូរ៉ូបាបិលគឺជាពូជរបស់ស្តេចដាវីឌ។ ដូច្នេះ សេចក្តីសន្យានៅក្នុងខ.២០-២៣ បង្ហាញថា ទ្រង់នឹងសំរេចតាមព្រះបន្ទូលសន្យារបស់ទ្រង់ចំពោះដាវីឌមែន។ ព្រះជាម្ចាស់នឹងទម្លាក់ស្តេចរបស់នគរទាំងឡាយ (ខ.២២) ប៉ុន្តែទ្រង់នឹងការពារសូរ៉ូបាបិល (ខ.២៣)។ ព្រះបន្ទូលសន្យាដែលថា ទ្រង់នឹងតែងតាំងសូរ៉ូបាបិលអោយធ្វើជាត្រារបស់ព្រះអង្គបានទទួលពូជរបស់ដាវីឌម្តងទៀត (សូមប្រៀបធៀប យេរេមា ២២:២៤)។ ទីបំផុតអត្ថបទនេះបានទាយពីព្រះគ្រីស្ទជាពូជរបស់ស្តេចដាវីឌដែលគ្រប់គ្រងអស់កល្បជានិច្ច (លូកា ១:៣២-៣៣)។
**សំនួរប្រឹក្សា** *តើ ២:១០-២៣ បានបង្រៀនអ្វីខ្លះអំពីព្រះជាម្ចាស់?*

**រំលឹកឡើងវិញ៖** *តើយើងបានរៀនអ្វីខ្លះចេញពីហាកាយ ២:១០-២៣?*